ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# តាងនាមប្រជារាស្ត្រខ្មែរ

សំណុំរឿងព្រហ្មទណ្ឌ

លេខ:១០៣៨/២៥-១១-២០១៣

សាលដីកា

លេខ:១៥ក្រVI(ធ)/១១-៤-២០១៤

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តីដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ០៦ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍នារសៀលថ្ងៃទី១១-៤-២០១៤ ដែលមានសមាសភាពដូចតទៅ:

<u>សមាសភាពក្រុមប្រឹក្សា</u>

| | | |
|---|---|---|
| លោក | [redacted] | ជាប្រធានក្រុមប្រឹក្សា |
| លោក | [redacted] | ជាចៅក្រមប្រឹក្សា |
| លោក | [redacted] | ជាចៅក្រមប្រឹក្សា |

<u>តំណាងមហាអយ្យការ</u>

លោក [redacted] ជាព្រះរាជអាជ្ញា

<u>ក្រឡាបញ្ជីសវនាការ</u>

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ:១០៣៨ ចុះថ្ងៃទី២៥-១១-២០១៣៖

-ជនជាប់ចោទឈ្មោះ [redacted] សុចិត្រ ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ មុខរបរសិស្ស កើតនៅសង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ មានទីលំនៅបច្ចុប្បន្ន [redacted] ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted](រ) នៅលីវ ទោសពីមុនគ្មាន (ជាដើមបណ្តឹងឧទ្ធរណ៍ និងជាម្ចាស់បណ្តឹងសាទុក្ខ ) (ឃុំខ្លួននៅត្រពាំងផ្លុង)

មេធាវីការពារលោក [redacted] អង រតន:

<u>**ត្រូវចោទពីបទ:ប្លន់(ឆក់ខ្សែក)**</u> ប្រព្រឹត្តនៅចំណុចភ្លើងស្តុបផ្លូវស្ពានអូរឫស្សី ខណ្ឌ៧មករា រាជធានីភ្នំពេញ  កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

<u>**ឯរឿងហេតុមានដូចតទៅ:**</u>

កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៨ វេលាម៉ោងប្រហែល១៥ ឈ្មោះ [redacted] សុចិត្រ និងឈ្មោះ [redacted] សុខហេង  បានធ្វើសកម្មភាពឆក់ខ្សែកពីជនរងគ្រោះ  ត្រង់ចំណុចភ្លើងស្តុបផ្លូវស្ពានអូរឫស្សី  ខណ្ឌ៧មករា៚/





Scanned with CamScanner

រាជធានីភ្នំពេញ អ្នកជិះខាងក្រោយគឺឈ្មោះ [redacted] សុខហេង ជាអ្នកឆក់ ។ ក្រោយពីឆក់មកក៏ជិះម៉ូតូគេចខ្លួនតែម្តង ហើយយកទៅលក់នៅផ្សារបឹងកេងកង ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខ:៧៩(ក្រ១) ចុះថ្ងៃទី២៥-០៦-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសំរេចសេចក្តីដូចខាងក្រោម:

១-ផ្តន្ទាទោស:

ក/-ឈ្មោះ [redacted] សុចិត្រ ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល០៥ឆ្នាំ(ប្រាំឆ្នាំ) គិតបន្តពីសាលក្រមមុន។

ខ/-ឈ្មោះ [redacted] សុខហេង ភេទប្រុស អាយុ១៥ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល០២ឆ្នាំ(ពីរឆ្នាំ) គិតបន្តពីសាលក្រមមុន ។

ពីបទ:ប្លន់(ឆក់ខ្សែក) ប្រព្រឹត្តនៅត្រង់ចំណុចភ្លើងស្តុប ផ្លូវល្ពោះអូរឫស្សី ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤-០៩-២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងតាមមាត្រា៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និង អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ។

២-សាលក្រមនេះជំនុំជំរះ នៅថ្ងៃទី០៥-០៦-២០០៩ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៥-០៦-២០០៩ ចំពោះមុខជនជាប់ចោទ និង មេធាវីការពារជនជាប់ចោទ បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញសាលដីកាព្រហ្មទណ្ឌលេខ:៩៧(ជ) ចុះថ្ងៃទី១១-១១-២០១០ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីដូចខាងក្រោម៖

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ:៣២២ ចុះថ្ងៃទី២០-០៧-២០០៩ របស់ជនជាប់ចោទឈ្មោះ [redacted] សុចិត្រ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ:៧៩ ក្រ១ ចុះថ្ងៃទី២៥-៦-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។

៣-បង្គាប់អោយបន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។

៤-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខមេធាវីការពារជនជាប់ចោទ ចំពោះមុខ [redacted] សុចិត្រ ។ បើកផ្លូវប្តឹងសាទុក្ខ តាមកំណត់ច្បាប់ ។

បានឃើញសាលដីកាលេខ:២១៤ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៣ របស់តុលាការកំពូល ដែលបានសម្រេចសេចក្តីដូចខាងក្រោម៖

១-ទទួលផ្នែកខ្លះនៃបណ្តឹងសារទុក្ខលេខ:២១៧ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១០ របស់ភាគីជនត្រូវចោទ។

២-បដិសេធពាក្យសុំស្រូបទោស ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១២ របស់ភាគីជនជាប់ចោទ ។

២០៨



Scanned with CamScanner

៣-តម្កល់សាលដីកាព្រហ្មទណ្ឌលេខៈ៣៦ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ លើកលែងតែចំណុចស្ដីពីការប្រកាសទោស ត្រូវបដិសេធចោល ។

៤-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខៈ១១៥ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១២ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះសារជាថ្មី អំពីចំណុចដូចខាងលើនេះ ។

៥-សាលដីការនេះជំនុំជម្រះនៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០១៣ ។

បានឃើញរបាយការណ៍រឿងចុះថ្ងៃទី២៥.០២.២០១៤ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍

បានឃើញសេចក្ដីសន្និដ្ឋានបន្ថែមចុះថ្ងៃទី២០-៣-២០១៤ របស់ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

**នាពេលសវនាការ**

ប្រធានក្រុមប្រឹក្សាសង្ខេបរឿងក្ដី

-ជនជាប់ចោទឈ្មោះ ញឹម សុចិត្រ(អវត្តមាននៅត្រពាំងថ្លុង)

-ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ [redacted] សុចិត្រ

-តំណាងមហាអយ្យការសន្និដ្ឋានថា: សូមសភាព្រហ្មទណ្ឌពិនិត្យនិងសម្រេច តាមការចង្អុលបង្ហាញរបស់តុលាការកំពូល ។

-មេធាវីលោក [redacted] អេងរតនៈ កាពារជនជាប់ចោទសន្និដ្ឋានថា: ខ្លួនយល់ស្របដូចដែលលោកតំណាងមហាអយ្យការបានសន្និដ្ឋានចង្អុលបង្ហាញរួចហើយ ហេតុនេះសូមសាលាឧទ្ធរណ៍ កែប្រែបទចោទប្រកាន់កូនក្ដីខ្លួនពីបទប្លន់តាមមាត្រា៦ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសមកមាត្រា១០, ៣៥៣ និង ៣៥៦ នៃក្រមព្រហ្មទណ្ឌវិញ ព្រោះបានចូលជាស្ថាពរហើយ ។

-ក្រោយពីបានស្ដាប់អំណានចម្លើយជនជាប់ចោទ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារដែលពាក់ពន្ធ័

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សាលាឧទ្ធរណ៍**

**យល់ឃើញថា**

១-សំណុំរឿងព្រហ្មទណ្ឌលេខៈ១០៣៨ ចុះថ្ងៃទី២៥.១១.២០១៣ របស់សាលាឧទ្ធរណ៍ ត្រូវបានតុលាការកំពូលបង្វិលមកសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះជាថ្មីឡើងវិញ ដោយអំណាចសាលដីកាព្រហ្មទណ្ឌលេខៈ២១៤ របស់តុលាការកំពូល ដូច្នេះសាលាឧទ្ធរណ៍ទទួលជំនុំជម្រះបានតាមច្បាប់ ។

២០៩



Scanned with CamScanner

២-តុលាការកំពូលបានទទួលស្គាល់ពីភាពមានពិរុទ្ធលើជនជាប់ចោទឈ្មោះ [redacted] សុចិត្រ នេះហើយ ហើយតុលាការកំពូលបានបង្វិលមកសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះជាថ្មីឡើងវិញ តែលើចំណុចស្ដីពីការប្រកាសទោស ដែលជនជាប់ចោទគប្បីបានទទួលអត្ថប្រយោជន៍តាមមាត្រា១០ នៃក្រមព្រហ្មទណ្ឌ ដូច្នេះ សាលាឧទ្ធរណ៍លើកយកតែចំណុចស្ដីពីការប្រកាសទោសនេះ មកធ្វើការពិចារណាតែប៉ុណ្ណោះ ។

៣-ជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទប្លន់ តាមមាត្រា៦ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ប៉ុន្តែតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលបានចូលជាធរមាន ក្រោយប្រព្រឹត្តរបស់ជនជាប់ចោទនេះ គឺអំពើប្រព្រឹត្តនេះជាបទល្មើសលួច ដែលត្រូវផ្ដន្ទាទោសតាមមាត្រា៣៥៣ និង៣៥៦ នៃក្រមព្រហ្មទណ្ឌ ដែលបានកំរិតនៃការផ្ដន្ទាទោសស្រាលជាងច្បាប់ចាស់ ហើយតាមមាត្រា១០ នៃក្រមព្រហ្មទណ្ឌថ្មីនេះ បានកំណត់ថាបទបញ្ញត្តិថ្មីដែលចែងអំពីទោសស្រាលជាងត្រូវអនុវត្តភ្លាម ដូច្នេះជនជាប់ចោទត្រូវបានទទួលអត្ថប្រយោជន៍ពីក្រមព្រហ្មទណ្ឌថ្មីនេះ ។

**ហេតុដូច្នេះវិនិច្ឆ័យសេចក្ដី**

១-ទទួលជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ:១០៣៨ ចុះថ្ងៃទី២៥.១១.២០១៣ របស់សាលាឧទ្ធរណ៍ ដោយអំណាចសាលដីកាព្រហ្មទណ្ឌលេខ:២១៤ របស់តុលាការកំពូល ។

២-កែប្រែបទចោទប្រកាន់លើជនជាប់ចោទក្នុងចំណុចទី១ នៃសេចក្ដីសម្រេចរបស់សាលក្រមព្រហ្មទណ្ឌលេខ:៧៩(ក្រ១) ចុះថ្ងៃទី២៥.០៦.២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ពីបទប្លន់ ដែលត្រូវផ្ដន្ទាទោសតាមមាត្រា៦ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោស មកជាបទលួច ដែលត្រូវផ្ដន្ទាទោសតាមមាត្រា៣៥៣ និង ៣៥៦ នៃក្រមព្រហ្មទណ្ឌ និង កែប្រែរយៈពេលនៃការផ្ដន្ទាទោសលើជនជាប់ចោទ ក្នុងចំណុចទី១ ដដែលនេះ ពីការផ្ដន្ទាទោសដាក់ពន្ធនាគាររយៈពេល០៥(ប្រាំ)ឆ្នាំ មកជារយៈពេល០៣(បី)ឆ្នាំវិញ ។ ចំណុចក្រៅពីនេះរក្សាទុកជាបានការដដែល។

៣-សាលដីកានេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ កំបាំងមុខជនជាប់ចោទ បើកផ្លូវប្ដឹងតវ៉ាតាមកំណត់ច្បាប់ ។ល។

សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ គ្រប់តំណែង និង កងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។ល។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

៧១០

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី...22...ខែ...5...ឆ្នាំ២០14
ក្រឡាបញ្ជី
[redacted]